សេចក្តីប្រកាសព័ត៌មានរួម

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៦

Water Song៖ ការអបអរសាទរទឹក វប្បធម៌ និងទំនាក់ទំនង

ក្រុមសៀក ARC Circus មកពីប្រទេសអូស្ត្រាលី និងក្រុមល្ខោនសៀកកម្ពុជា ហ្វារ មកពីប្រទេសកម្ពុជា បានសហការគ្នានាំយកការសម្តែងជាលើកដំបូងបង្អស់លើពិភពលោកនៃស្នាដៃសិល្បៈសៀកដែលមានចំណងជើងថា «Water Song»។ នេះជាកិច្ចសហការផ្នែកសិល្បៈសៀកដ៏ពិសេសមួយ ដែលស្វែងយល់អំពីទំនាក់ទំនងរួមដ៏ជ្រាលជ្រៅ និងពិសិដ្ឋរបស់មនុស្សជាតិជាមួយនឹងទឹក។

ដោយមានការចូលរួមពីសិល្បករសម្តែងសៀកចំនួន ១១ នាក់ និងក្រុមសិល្បៈការងារច្នៃប្រឌិតជាង ៣០ នាក់ មកពីប្រទេសអូស្ត្រាលី និងកម្ពុជា «Water Song» នឹងសម្តែងជាលើកដំបូងនៅវេលាម៉ោង ៥:០០ ល្ងាច ថ្ងៃព្រហស្បតិ៍ ទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅខេត្តសៀមរាប ក្នុងមហោស្រពសៀកថ្នាក់ជាតិរបស់កម្ពុជា ដែលមានឈ្មោះថា «ទីនេះ ទីនោះ»។

ស្នាដៃ Water Song ត្រូវបានរៀបរាប់តាមរយៈឈុតឆាកសម្តែងសៀកជាបន្តបន្ទាប់ ដោយឆ្លុះបញ្ចាំងពីតួនាទីរបស់ទឹកនៅក្នុងវប្បធម៌ផ្សេងៗ ចាប់ពីផ្ទៃដីដ៏ធំល្វឹងល្វើយ និងសួតហួតហែងក្រោមកម្តៅថ្ងៃរបស់ប្រទេសអូស្ត្រាលី រហូតដល់ការមកដល់ដ៏គួរឱ្យកត់សម្គាល់នៃរដូវវស្សានៅកម្ពុជា។ ដោយទាញយកការបំផុសគំនិតពីរូបភាពនៃរបាំប្រពៃណី ទេវកថាវប្បធម៌ និងការនិទានរឿងអំពីបរិស្ថានពីប្រទេសទាំងពីរ ស្នាដៃនេះបង្ហាញពីភាពស្រដៀងគ្នាដែលមិននឹកស្មានដល់ រវាងប្រពៃណីសិល្បៈ និងរបៀបនៃការសម្តែងពីរដែលមានលក្ខណៈខុសប្លែកគ្នា។

ក្រៅពីការសម្តែងលើឆាក កិច្ចសហការនេះក៏រួមបញ្ចូលសិក្ខាសាលាដែលភ្ជាប់សិល្បករ និងសហគមន៍នានានៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ ដើម្បីលើកកម្ពស់ការយល់ដឹងកាន់តែស៊ីជម្រៅអំពីប្រពៃណីវប្បធម៌របស់ប្រទេសជិតខាង។ ដូច្នេះ «Water Song» មិនត្រឹមតែជាកិច្ចសហការផ្នែកសិល្បៈប៉ុណ្ណោះទេ ប៉ុន្តែក៏ជាគម្រោងដែលជួយពង្រឹងទំនាក់ទំនងនៅក្នុងតំបន់ផងដែរ។

«Water Song» ទទួលបានការគាំទ្រពី មជ្ឈមណ្ឌលអាស៊ាន-អូស្ត្រាលី (ASEAN-Australia Centre) ស្ថាប័ន Creative Australia និងរដ្ឋបាលក្រុង Gold Coast ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរួមគ្នាក្នុងការពង្រឹងទំនាក់ទំនងផ្នែកវប្បធម៌ និងការច្នៃប្រឌិតរវាងប្រទេសអូស្ត្រាលី និងតំបន់អាស៊ីអាគ្នេយ៍។

ឯកឧត្តម ដេរីក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖ «អូស្ត្រាលីកំពុងគាំទ្រ Water Song ដែលជាកិច្ចសហការដ៏ពិសេសមួយ នាំសិល្បករអូស្ត្រាលី និងកម្ពុជាមករួមគ្នាតាមរយៈភាពច្នៃប្រឌិត និងទំនាក់ទំនងរួមជាមួយនឹងទឹក។ កិច្ចសហការនេះ គឺជាការលើកតម្កើងវប្បធម៌របស់យើងទាំងពីរ ការកសាងមិត្តភាព ការពង្រឹងទំនាក់ទំនងរវាងប្រជាជននៃប្រទេសទាំងពីរ និងបន្តនូវទំនាក់ទំនងការទូត និងមិត្តភាពរយៈពេល ៧៥ ឆ្នាំ ដែលយើងនឹងប្រារព្ធឡើងនៅឆ្នាំ២០២៧ ខាងមុខនេះ»។

លោក Robbie Curtis នាយកសិល្បៈនៃក្រុមសៀក ARC Circus បានមានប្រសាសន៍ថា៖ «យើងពិតជារំភើបណាស់ដែលបានសហការជាមួយក្រុមល្ខោនសៀកកម្ពុជា ហ្វារ ដើម្បីបង្កើតការសម្តែងថ្មីរបស់យើង «Water Song» និងពង្រឹងទំនាក់ទំនងនៅទូទាំងតំបន់អាស៊ាន តាមរយៈការផ្លាស់ប្តូរជំនាញ។ ចំណង់ចំណូលចិត្តរួមរបស់យើងចំពោះសិល្បៈសៀក ចលនារាងកាយ និងវប្បធម៌ ត្រូវបានបញ្ចូលគ្នាទៅក្នុងស្នាដៃនេះ ហើយយើងសង្ឃឹមថា វានឹងនាំមកនូវភាពរីករាយ និងការតភ្ជាប់ទំនាក់ទំនងដល់ទស្សនិកជនទាំងអស់ដែលបានទស្សនា»។

លោក Osman Khawaja នាយកប្រតិបត្តិនៃល្ខោនសៀកកម្ពុជា ហ្វារ បានមានប្រសាសន៍ថា៖ «យើងពិតជារំភើបចំពោះការរួមគ្នាបង្កើតស្នាដៃនេះជាមួយក្រុមសៀក ARC Circus ដែលជាកិច្ចសហការលើកដំបូងបង្អស់ក្នុងទម្រង់នេះ ដោយមានសិល្បករមកពីប្រទេសកម្ពុជា និងអូស្ត្រាលីសម្តែងរួមគ្នា។ កិច្ចសហការនេះកំពុងបង្កើតឱកាសថ្មី។ ពង្រីកវិសាលភាពនៃគំនិតច្នៃប្រឌិត និងកសាងទំនាក់ទំនងឱ្យកាន់តែស៊ីជម្រៅ និងមានអត្ថន័យ។ យើងមានសេចក្តីរីករាយយ៉ាងខ្លាំងដែលបានធ្វើការជាមួយក្រុមការងារអូស្ត្រាលី ហើយពួកគេក៏បានចែករំលែកជំនាញ និងបទពិសោធន៍របស់ពួកគេជាមួយយើង។ យើងសម្លឹងឆ្ពោះទៅកាន់ដំណើរនៃការសម្តែងរួមគ្នា ដើម្បីនាំយកស្នាដៃ «Water Song» ទៅកាន់ទស្សនិកជនជុំវិញពិភពលោក ព្រមទាំងចែករំលែកចំណងវប្បធម៌ដ៏ពិសេសនេះផងដែរ»។

លោកស្រី Fiona Hoggart ប្រធានមជ្ឈមណ្ឌលអាស៊ាន-អូស្ត្រាលី (ASEAN-Australia Centre) បានមានប្រសាសន៍ថា៖ «Water Song បង្ហាញឱ្យឃើញពីថាមពលនៃកិច្ចសហការប្រកបដោយភាពច្នៃប្រឌិត ក្នុងការនាំប្រជាជនអូស្ត្រាលី និងអាស៊ីអាគ្នេយ៍ឱ្យកាន់តែជិតស្និទ្ធគ្នា។ តាមរយៈការតភ្ជាប់សិល្បករ អ្នកច្នៃប្រឌិត និង

សហគមន៍នានានៅទូទាំងតំបន់ ភាពជាដៃគូនេះកំពុងពង្រឹងទំនាក់ទំនងរវាងប្រជាជន និងប្រជាជន ព្រមទាំងបង្កើតឱកាសថ្មីៗសម្រាប់ការផ្លាស់ប្តូរវប្បធម៌ ដែលនឹងបន្តទៅលើសពីឆាកសម្តែង»។

អំពីក្រុមសៀក ARC Circus

ARC Circus គឺជាក្រុមហ៊ុនសិល្បៈសម្តែងអន្តរជាតិមួយដែលមានមូលដ្ឋាននៅទីក្រុង Gold Coast ប្រទេសអូស្ត្រាលី និងទទួលបានពានរង្វាន់នានា។ ក្រុមហ៊ុននេះត្រូវបានទទួលស្គាល់តាមរយៈគម្រោងកិច្ចសហការឆ្លងវប្បធម៌ ក៏ដូចជាស្នាដៃសិល្បៈសៀកបែបសហសម័យរបស់ខ្លួន។

អំពីល្ខោនសៀកកម្ពុជា ហ្វារ

ល្ខោនសៀកកម្ពុជា ហ្វារ ដែលល្បីល្បាញខាងការនិទានរឿងដ៏មានអត្ថន័យជ្រាលជ្រៅ និងការសម្តែងសៀកដែលទទួលបានការកោតសរសើរជាអន្តរជាតិ គឺជាសហគ្រាសសង្គមមួយរបស់អង្គការហ្វាពន្លឺសិល្បៈ ដែលជាអង្គការមិនមែនរដ្ឋាភិបាលមិនស្វែងរកប្រាក់ចំណេញ មានមូលដ្ឋាននៅខេត្តបាត់ដំបង និងជួយលើកកម្ពស់ជីវភាពរស់នៅតាមរយៈសិល្បៈ។

អំពីមជ្ឈមណ្ឌលអាស៊ាន-អូស្ត្រាលី (ASEAN-Australia Centre)

បេសកកម្មរបស់មជ្ឈមណ្ឌលអាស៊ាន-អូស្ត្រាលី គឺដើម្បីពង្រឹងទំនាក់ទំនងរវាងប្រទេសអូស្ត្រាលី និងតំបន់អាស៊ីអាគ្នេយ៍ ឆ្ពោះទៅរកគោលដៅនៃសន្តិភាព ស្ថិរភាព និងវិបុលភាព។ មជ្ឈមណ្ឌលនេះអនុវត្តកម្មវិធី និងគំនិតផ្តួចផ្តើមនានា ក្រោមសសរស្តម្ភយុទ្ធសាស្ត្រចំនួនបួន រួមមាន៖ ការលើកកម្ពស់ការយល់ដឹងអំពីអាស៊ីអាគ្នេយ៍ ទំនាក់ទំនងសេដ្ឋកិច្ច ការអប់រំ និងទំនាក់ទំនងវប្បធម៌។

ទំនាក់ទំនងព័ត៌មាន៖

- **ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា៖** Media.Cambodia@dfat.gov.au
- **ក្រុមសៀក ARC Circus៖** lizzie@arccircus.com
- **ល្ខោនសៀកកម្ពុជា ហ្វារ៖** ponlork.v@phareps.org